# សេចក្ដីប្រកាសព័ត៌មាន

# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១២

ស្ថានទូតជប៉ុនរួមសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន ក្រោមកិច្ចសហការឧបត្ថម្ភពីសាលាអូរីហ្គាមីនិងសមាគមជនជាតិជប៉ុននៅកម្ពុជា បានរៀបចំកម្មវិធីប្រលងចម្រៀងណូដូជីម៉ាន់ ”**មោទនភាពសំលេង**” សម្រាប់ សិស្ស និស្សិត ដែលសិក្សាភាសាជប៉ុន។

ស្ថានទូតទទួលបានការដាក់ពាក្យចូលរួមពីបេក្ខជនទាំងនៅទីក្រុងភ្នំពេញ និងសៀមរាបមានចំនួនសរុបចំនួន១៤៧នាក់។ បន្ទាប់ពីការប្រលងជ្រើសរើសវគ្គទី១ នៅថ្ងៃទី៨ ខែមករា មានបេក្ខជន១៥នាក់ ត្រូវបានជ្រើសរើសដើម្បីចូលរួមការប្រលងផ្ដាច់ព្រ័ត្រដែលបានធ្វើឡើងនៅថ្ងៃអាទិត្យ ទី១៥ ខែមករា នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន។ កម្មវិធីប្រលងផ្ដាច់ព្រ័ត្រនេះបានប្រព្រឹត្តិទៅក្នុងបរិយាកាសដ៏សប្បាយរីករាយ និងអំណរសាទរដោយមានអ្នកចូលរួមគាំទ្រជាង ៤០០នាក់។

បេក្ខជនទទួលបានជ័យលាភីនៅក្នុងឆ្នាំនេះ គឺជានិស្សិតមកពីវិទ្យាស្ថានភាសាបរទេស លោក **ថេត ចាន់សុធា** ច្រៀងបទដែលមានចំណងជើងថាសាគូរ៉ា។ អ្នកជាប់ជ័យលាភីលេខ២បានទៅលើកញ្ញា **ខិន សុភា** ជាសិស្សមកពីសាលាពាណិជ្ជសាស្ត្រកម្ពុជា-ជប៉ុន និង អ្នកជាប់ជ័យលាភីលេខ៣ បានទៅ លើកញ្ញា **អ៊ុក ស្រីមុំ** មកពីសាលាពាណិជ្ជសាស្ត្រកម្ពុជា-ជប៉ុនផងដែរ។ ស្ថានទូតក៏បានប្រគល់រង្វាន់ពិសេសដល់ក្រុមអ្នកចំរៀងដែលសម្ដែងកាយ វិការបានល្អបំផុតទៅក្រុមលោក **មួង សុជាត** និងមិត្តរួមក្រុមមកពីសាលាពាណិជ្ជសាស្ត្រតាយ៉ាម៉ា ហើយចំពោះរង្វាន់សម្រាប់អ្នកបញ្ចេញសំលេងជាភាសាជប៉ុនល្អបំផុតបានទៅលើកញ្ញា **ហៃ សុជាតា** មកពីក្រុមហ៊ុនទេសចរណ៍អង្គរ ជី អេច ស៊ី សៀមរាប។

ជានិច្ចកាល ការចូលរួមនៅក្នុងការប្រលងប្រជែងថ្លែងសុន្ទរកថាភាសាជប៉ុន គឺមានភាពលំបាកសម្រាប់អ្នកសិក្សាភាសាជប៉ុនកំរិតដំបូង។ យ៉ាងណាក៏ដោយ ការចូលរួម និងការទទួលបាននូវជោគជ័យនៅក្នុងការប្រលងចំរៀងជប៉ុន គឺមានភាពងាយស្រួល និងមានភាពសប្បាយរីករាយជាង។ អាស្រ័យហេតុនេះ កម្មវិធីប្រលងចម្រៀងណូដូជីម៉ាន់ នឹងដើរតួនាទីក្នុងការលើកទឹកចិត្តដល់សិស្សនិស្សិតដែលសិក្សាភាសាជប៉ុននៅគ្រប់

កិរិតដើម្បីហាត់ច្រៀងចម្រៀងជាភាសាជប៉ុន។ ជាពិសេសទៅទៀតនោះគឺការច្រៀងចម្រៀងជប៉ុនដែលកំពុងពេញនិយមនៅក្នុងប្រទេសកម្ពុជា ហើយយើងសង្ឃឹមថាការយល់ដឹងពីវប្បធម៌ជប៉ុន និងភាសាជប៉ុនក្នុងចំណោមប្រជាជនកម្ពុជា នឹងត្រូវបានជម្រុញបន្ថែមតាមរយៈកម្មវិធីប្រលងចម្រៀងនេះ។



**រូបថត អ្នកចូលរួមគាំទ្រ**

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: ០២៣ ២១៧ ១៦១ ទូរសារ: ០២៣ ២១០ ៣៨៤

អ៊ីម៉ែល: info.jpn@pp.mofa.go.jp គេហទំព័រ: http://www.kh.emb-japan.go.jp